**បកប្រែក្រៅផ្លូវការ**

# សុន្ទរកថា
# របស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
# ក្នុងឱកាសទិវាបុណ្យជាតិបារាំង ១៤កក្កដា
# ស្ថានទូតបារាំង ១៤កក្កដា ២០១៦

-សូមគោរព ឯកឧត្តមឯកអគ្គរដ្ឋទូតបារាំង និងលោកជំទាវ ហ្សង់-ក្លូដ ពាំបឺហ្វ
-សូមក្រាបថ្វាយបង្គំ ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់
-ឯកឧត្តម លោកជំទាវ
-អស់លោក លោកស្រី

ថ្ងៃនេះ យើងប្រារព្ធបុណ្យជាតិបារាំង ហើយខ្ញុំមានឱកាសចូលរួមក្នុងនាមតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលមានធុរៈនៅបរទេស ដោយសារលោកត្រូវចូលរួមកិច្ចប្រជុំកំពូលអាស៊ី អឺរ៉ុប ហើយខ្ញុំមានកិត្តិយសពាំនាំនូវការសម្តែងនូវមិត្តភាពដ៏កក់ក្តៅពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាចំពោះប្រទេស និងប្រជាជនបារាំង។

ចំណងដែលផ្សារភ្ជាប់ប្រទេស និងប្រជាពលរដ្ឋយើងទាំងពីរមានតាំងពីយូរណាស់មកហើយ ហើយចាក់ឬសក្នុងប្រវត្តិសាស្ត្រដ៏យូរលង់ ដែលមានអាយុកាលជាង១៥០ឆ្នាំហើយមកទល់ពេលនេះ។ យើងមិនភ្លេចទេថា នៅពេលបារាំង និងកម្ពុជាបានបិទបញ្ចប់ដោយការព្រមព្រៀង និងសន្តិភាព នូវអាណាព្យាបាលអាយុកាល៩០ឆ្នាំ ដែលពេលខ្លះមានលក្ខណៈរឹងត្អឹង ដោយសារប្រទេសបារាំង ផ្ទៃដីកម្ពុជាបានកើនធំជាងមុនក្រោយពេលទទួលបានមកវិញនូវខេត្តទាំងបី គឺស៊ីសុផុន បាត់ដំបង និងសៀមរាបនៅឆ្នាំ១៩០៧។ យើងក៏មិនភ្លេចផងដែរចំពោះសាលាបារាំងចុងបូព៌ា ដែលបានស្រាវជ្រាវកាប់ឆ្ការរកឃើញប្រាសាទអង្គរ និងធនធានបេតិកភណ្ឌសិល្បៈប្រវត្តិសាស្ត្រដ៏មានតម្លៃដទៃទៀត ដែលបានធ្វើអោយកម្ពុជាទទួលបានមោទនភាពជាតិឡើងវិញ។

បន្ទាប់ពីទទួលបានឯករាជ្យ កម្ពុជាបានបន្តរក្សាទំនាក់ទំនងដ៏ស្អិតរមួតជាមួយប្រទេសបារាំង ក្រោមការជំរុញរបស់សម្តេចព្រះបិតាព្រះបាទនរោត្តម សីហនុ។ ទំនាក់ទំនងនេះបានជួបប្រទះនូវដំណាក់កាលពិសេសមួយនៅពេលប្រធានធិបតីដឺហ្គោល បានអញ្ជើញមកថ្លែងសុន្ទរកថាមួយ ហៅថា "សុន្ទរកថាភ្នំពេញ" ដែលបានចារិកក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា បារាំង និងពិភពលោក។
ដោយមានសំណូមពរពីឯកឧត្តមឯកអគ្គរដ្ឋទូត នៅឆ្នាំនេះ យើងនឹងប្រារព្ធខួបទី៥០នៃដំណើរទស្សនកិច្ចរបស់ប្រធានាធិបតីដឺហ្គោលមកភ្នំពេញ ដែលបានចារិកក្នុងទំនាក់ទំនងប្រទេសយើងទាំងពីរ។

ខ្ញុំបានអានសុន្ទរកថាដ៏សែនមានអត្ថន័យនេះជាថ្មីម្តងទៀត ហើយខ្ញុំរំភើបចំពោះពាក្យពេចន៍ ដែលនៅតែមានន័យនៅពេលនេះ។ លោកឧត្តមសេនីយ៍ដឺហ្គោលបានលើកឡើងថា៖ «គ្មានផ្លូវដែលពលរដ្ឋអាស៊ីសុខចិត្តស្ថិតក្រោមគំនាបនៃច្បាប់បរទេសដែលមកពីត្រើយម្ខាងទៀតនៃមហាសមុទ្រប៉ាស៊ីហ្វិកនោះទេ ទោះបីជាប្រទេសទាំង

នោះមានបំណង និងអាវុធខ្លាំងខ្លាបែបណាក៏ដោយ»។ នៅក្នុងពិភពលោកមួយ ដែលការតស៊ូប្រឆាំងនឹងការវិវឌ្ឍន៍ទៅរកពហុប៉ូល បង្កើតអោយមានភាពតានតឹងថ្មីៗ ពាក្យពេចន៍ដែលលោកប្រធានាធិបតីបារាំងបានថ្លែងបានល្បីខ្ទរខ្ទារជាមួយអ្វីដែលកើតឡើងនៅពេលបច្ចុប្បន្ន។

បន្ទាប់ពីមានសោកនាដកម្មដ៏ធំធេងក្នុងអំឡុងឆ្នាំ៧០ និងការឈឺចាប់នៃភាពឯកោរបស់យើងនៅទសវត្សបន្ទាប់មកទៀត ប្រទេសបារាំងបានរួមចំណែកដ៏ធំធេងក្នុងការស្វែងរកដំណោះស្រាយនយោបាយមួយ ដែលអាចអោយប្រទេសកម្ពុជាធ្វើសមាហរណកម្មសាជាថ្មីទៅក្នុងសហគមន៍អន្តរជាតិ។

យើងនៅចងចាំថា គឺនៅប្រទេសបារាំងដែលកើតមានជំនួបដំបូងរវាងសម្តេចតេជោ ហ៊ុន សែន ដែលកាលនោះជាប្រធានក្រុមប្រឹក្សារដ្ឋនៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា និងព្រះអង្គម្ចាស់នរោត្តម សីហនុ។ អ្វីៗបានប្រព្រឹត្តទៅនៅ Fère en Tardenois ហើយក៏ជាអនុស្សាវរីយ៍ដ៏មានតម្លៃចំពោះខ្ញុំ ដោយសារកាលនោះខ្ញុំអមដំណើរសម្តេចនាយករដ្ឋមន្ត្រីក្នុងជំនួបនេះ។ យើងមិនភ្លេចពី តួនាទីសំខាន់របស់រដ្ឋមន្ត្រីក្រសួងការបរទេសបារាំង លោក រ៉ូឡង់ ឌុយម៉ាស ក្នុងអំឡុងនៃកាចរចា និងការសម្របសម្រួលជាវិជ្ជមានរបស់លោកឯកអគ្គរដ្ឋទូត ហ្សង់ ដាវីត ឡឺវីត ដែលកាលនោះជាថ្នាក់ដឹកនាំនាយកដ្ឋានអាស៊ីនៃក្រសួងការបរទេសបារាំង។

ចាប់តាំងពីឆ្នាំ១៩៩៣មក ប្រទេសយើងទាំងពីរបានរក្សានូវទំនាក់ទំនងដ៏ល្អប្រពៃ ដូចដែលយើងធ្លាប់បានឃើញនៅចន្លោះឆ្នាំ១៩៥៣ និង ១៩៧០។ យើងដឹងគុណចំពោះកិច្ចខិតខំប្រឹងប្រែងដ៏ច្រើនរបស់បារាំងក្នុងការជួយបណ្តុះបណ្តាលធនធានមនុស្សនៅកម្ពុជាឡើងវិញ ដែលបច្ចុប្បន្នកំពុងខ្វះខាតយ៉ាងខ្លាំងនៅឡើយ។

ប៉ុន្តែគេមិនចាំបាច់រង់ចាំអោយមានកិច្ចព្រមព្រៀងប៉ារីស ដើម្បីទទួលបានការយកចិត្តទុកដាក់ពីសំណាក់ប្រទេសបារាំងនោះទេ។ ក្នុងន័យនេះ ខ្ញុំនឹកជាពិសេសទៅដល់វិស័យសុខាភិបាល ដែលទទូលបានការគាំទ្រពីប្រទេសបារាំងតាំងពីមុនកិច្ចព្រមព្រៀងនេះទៅទៀត តាមរយៈលោកវេជ្ជបណ្ឌិត ម៉ី សាម៉ឺឌី បច្ចុប្បន្នបានទទួលអានិច្ចកម្មទៅហើយ ដែលបានកសាងកិច្ចសហប្រតិតបត្តិការ ដ៏មានប្រសិទ្ធភាពតាំងពីឆ្នាំ១៩៨០ ជាមួយមន្ទីរពេទ្យ Pitié-Saintpêtrière នៃទីក្រុងប៉ារីស ក្នុងពេលដែលប្រជាពលរដ្ឋកម្ពុជារងនូវការដាក់ទណ្ឌកម្មដោយគ្មានអាណិតអាសូរ។ គឺតាំងពីពេលនោះហើយដែលវិស័យសុខាភិបាលកម្ពុជាបានចាប់កំណើតឡើងវិញ ក្រោយជំនួយឧបត្ថម្ភជាបន្តបន្ទាប់ពីប្រទេសបារាំងរហូតមកដល់បច្ចុប្បន្ន។

ទាល់តែដល់ខែតុលា ឆ្នាំ១៩៩០ ទើបសាលា Alliance Française បានបើកទ្វារនៅភ្នំពេញ ហើយទទួលបានសិស្សកម្ពុជាជាច្រើនពាន់នាក់ចុះឈ្មោះរៀនភាសាបារាំង។

ក្រោយឆ្នាំ១៩៩៣ ប្រទេសបារាំងបានធ្វើកិច្ចសហប្រតិបត្តិការពីរមុខព្រួញក្នុងវិស័យសំខាន់មួយសម្រាប់ដំណើរឆ្ពោះទៅកាន់នីតិរដ្ឋរបស់កម្ពុជា នោះគឺការជួយបណ្តុះបណ្តាលអ្នកច្បាប់ផង និងផ្តល់កិច្ចសហការដ៏មានសារសំខាន់ក្នុងការធ្វើកំណែទម្រង់ក្រមសំខាន់ៗផង។ យើងមានបំណងអោយបារាំងបន្តកិច្ចសហប្រតិបត្តិការទាំងនោះ និងសូមអោយបារាំងផ្តល់អាហារូបករណ៍បន្ថែមទៀតដល់និស្សិតកម្ពុជាផ្នែកនីតិសាស្ត្រ ដោយហេតុថា ដូចយើងទាំងអស់គ្នាបានដឹងហើយថា ប្រជាធិបតេយ្យអាចមានដំណើរការស្ថិតស្ថេរទៅបាននៅក្នុងប្រទេសមួយ

ល្អិកណាពលរដ្ឋប្រទេសនោះ ទទួលបានការអប់រំក្នុងកម្រិតមួយ ហើយមានអ្នកច្បាប់ច្រើនដើម្បីជានាកុំអោយមានការរំលោភច្បាប់ ។

នៅមានវិស័យផ្សេងទៀតដែលប្រទេសបារាំងចូលរួមក្នុងការអភិវឌ្ឍប្រទេសកម្ពុជា។ ខ្ញុំអាចរៀបរាប់ដូចជាវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងការចូលរួមចំណែករបស់បារាំងក្នុងគម្រោងនានាដែលស្នើឡើងដោយស្ថាប័នអន្តរជាតិដូចជាអង្គការយូណេស្កូជាដើម។ ខ្ញុំក៏មិនភ្លេចផងដែរនូវសកម្មភាពជាច្រើនរបស់ទីភ្នាក់ងារអភិវឌ្ឍបារាំងក្នុងវិស័យកសិកម្ម ការអភិវឌ្ឍក្រុង សុខាភិបាល វប្បធម៌ ការផ្គត់ផ្គង់ទឹកស្អាត វាយនភណ្ឌ ទេសចរណ៍។ល។

ខ្ញុំមានសេចក្តីសប្បាយរីករាយណាស់ដែលបានលឺ ឯកឧត្តមឯកអគ្គរដ្ឋទូត លើកឡើងថា សិស្សសាលាដេកាតបានបំបែកឯតទគ្គកម្មពិភពលោក ដោយប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ១០០%! កាលពីសម័យខ្ញុំនៅរៀនគេមិនអាចធ្វើបានដូច្នេះឡើយ! ប៉ុន្តែរាល់ជនជាតិកម្ពុជា ទាំងស្រី ទាំងប្រុសដែលចេញពីសាលានេះ ខ្ញុំសូមនិយាយដោយមិនបញ្ជោឡើយថា ពួកគេជំនាន់មុនស្ថិតក្នុងចំណោមបុគ្គលឆ្នើមកម្ពុជា ហើយខ្ញុំសូមអោយមានដូចគ្នាដែរចំពោះសិស្សសាលាដេកាតបច្ចុប្បន្ន។

*-ឯកឧត្តមឯកអគ្គរដ្ឋទូតបារាំង និងលោកជំទាវ ហ្សង់-ក្លូដ ពាំបឺហ្វ*
*-ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់*
*-ឯកឧត្តម លោកជំទាវ*
*-អស់លោក លោកស្រី*

គុណបំណាច់របស់បារាំងចំពោះកម្ពុជា ប្រសិនបើចង់រៀបរាប់លម្អិត គឺគួរតែរៀបរាប់នៅក្នុងសន្និសីទមួយ មិនមែនក្នុងរាត្រីនេះ ដែលយើងប្រារព្ធរួមគ្នានូវបុណ្យជាតិរបស់ពលរដ្ឋបារាំង ប្រកបដោយលក្ខណៈមិត្តភាពនេះឡើយ។

នៅចុងបញ្ចប់នេះ ក្នុងនាមខ្ញុំផ្ទាល់ និងក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមប្រសិទ្ធពរដល់ប្រទេសបារាំង ដោយខ្ញុំសូមលើកយកពាក្យដែលលោកឧត្តមសេនីយ៍ដឺហ្គោលបានថ្លែងកាលពី៥០ឆ្នាំមុន គឺសូមជូនពរ «មិត្តភាពដ៏រស់រវើកនៃរដ្ឋាភិបាល និងប្រជាពលរដ្ឋប្រទេសយើងទាំងពីរ »។

ក្នុងទិវាបុណ្យជាតិបារាំងនេះ ខ្ញុំសូមគោរពអញ្ជើញលោកអ្នក លើកកែវឡើង

- ដើម្បីជូនពរដល់ឯកឧត្តម ហ្វ្រង់ស័រ ហូឡង់ ប្រធានាធិបតីសាធារណរដ្ឋបារាំង
- ដើម្បីព្រះរាជសុខភាពព្រះករុណាសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
- និងដើម្បីមិត្តភាព ភាពរុងរឿង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសយើងទាំងពីរ

ជយោប្រទេសបារាំង!
ជយោប្រទេសកម្ពុជា!
ជយោមិត្តភាព កម្ពុជា-បារាំង!